អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

**មាតិកា៖**

- ការនាំចេញគ្រាប់ស្វាយចន្ទីនៅក្នុងឆមាសទី១មានកំណើនជាង៣០០%
- វិបត្តិជំងឺកូវីដ១៩ មិនអាចរារាំងការងារបង្កបង្កើនផលស្រូវរបស់ប្រជាកសិករនៅខេត្តបាត់ដំបងឡើយ
- ៧ខែដំបូង ឆ្នាំ២០២១ កម្ពុជានាំចេញអង្ករ បានជាង៣០ម៉ឺនតោន ធ្លាក់ចុះជាង២៧%
- គិតត្រឹមឆមាសទី១ ពាណិជ្ជកម្មទ្វេភាគីរវាងម្ពុជា និងសហរដ្ឋអាមេរិកមានសន្ទុះកើនឡើងជាង៣២%
- សេដ្ឋកិច្ចហ្វីលីពីនកើនខ្លាំង ក្នុង៣ទសវត្សន៍មកនេះ ប៉ុន្តែមានឧបសគ្គដោយសារកូវីដ១៩
- ការអនុវត្តថវិការបស់ប្រទេសហ្វីលីពីនក្នុងឆមាសទី១ឆ្នាំ២០២១
- អ្នកកែច្នៃអាហារថៃ ស្នើសុំរដ្ឋ តម្លើងថ្លៃទំនិញ ៥% ទៅ ៧% ខណៈថ្លៃដើមកើនឡើងខ្លាំង
- វៀតណាម និងចិនចុះ MoU ជំរុញពាណិជ្ជកម្មផ្លែឈើ អំឡុងពេលមានផលរំខានពីកូវីដ-១៩
- ការវិនិយោគលើវិស័យដឹកជញ្ជូន និងអចលនទ្រព្យឧស្សាហកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក នឹងមានកំណើនទ្វេដង ក្នុងអំឡុងពេល៣ឆ្នាំ ទៅ ៥ឆ្នាំខាងមុខ
- បំណុលសាធារណៈសហរដ្ឋអាមេរិក កើនដល់ ២៨,៦ទ្រីលានដុល្លារ ដែលមានកំណើន ៥,២ទ្រីលានដុល្លារ គិតពីឆ្នាំ២០២០
- តម្លៃប្រេងឆៅបានធ្លាក់ចុះ ស្របពេលករណីមេរោគកូវីដ-១៩ ប្រភេទថ្មី(Delta) មានការកើនឡើងខ្លាំង
- IMF ព្យាករថា ចិននឹងជាក្បាលម៉ាស៊ីនទី១ជំរុញកំណើនសេដ្ឋកិច្ចពិភពលោក នៅក្រោយវិបត្តិកូវីដ-១៩
- ការនាំចេញរបស់ចិនងើបឡើងក្នុងខែកក្កដា ខណៈសកម្មភាពនៅកំពង់ផែស្ទះឡើងវិញ


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមវរៈ អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### ការនាំចេញគ្រាប់ស្វាយចន្ទីនៅក្នុងឆមាសទី១មានកំណើនជាង៣០០%



*ប្រភព៖ [ភ្នំពេញប៉ុស្តិ៍ ២០២១,រូបភាព ហុង មីនា]*

កម្ពុជា បាននាំចេញគ្រាប់ស្វាយចន្ទីចំនួនជាង ៨៦ ម៉ឺនតោន ក្នុងរយៈពេល ៧ ខែ ដើមឆ្នាំ ២០២១ កើនជាង ៣០០% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំមុន ហើយប្រទេសវៀតណាម គឺជាទីផ្សារធំជាងគេសម្រាប់គ្រាប់ស្វាយចន្ទីរបស់កម្ពុជា។

តាមទិន្នន័យពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានឱ្យដឹងថា ក្នុងរយៈពេល ៧ ខែដើមឆ្នាំនេះ កម្ពុជាបាននាំចេញគ្រាប់ស្វាយចន្ទីចំនួន ៨៦៦ ២០៧,៧៧ តោន កើនឡើង ៣៤៥,២៩ % បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។

សម្រាប់ទីផ្សារនៃការនាំចេញស្វាយចន្ទីធំជាងគេ គឺប្រទេសវៀតណាម ចំនួន៨៥៩ ២៩០ តោន, ប្រទេសចិន ៣ ៦៣៩,៥ តោន, ប្រទេសថៃ ៣ ១៩៩,៤០ តោន, ជប៉ុនចំនួន ៣៤,៤៣ តោន, ឥណ្ឌា ១៧ តោន, អារ៉ាប់ ១៤,៥១ តោន, បង់ក្លាដែស ៧ តោន, កូរ៉េ ៣,៩១ តោន, និងឡាវ ២ តោន។

បច្ចុប្បន្នរាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងរៀបចំសេចក្តីព្រាងគោលនយោបាយជាតិស្វាយចន្ទី ក្នុងគោលបំណងដើម្បីពង្រឹងសមត្ថភាពដាំដុះ និងការកែច្នៃផលិតផលស្វាយចន្ទី។ បន្ថែមពីនេះ គោលនយោបាយនេះក៏ដើម្បីប្រែក្លាយកម្ពុជាទៅជាប្រទេសផលិត និងផ្គត់ផ្គង់ផលិតផលស្វាយចន្ទីសម្រាប់ទីផ្សារក្នុងស្រុក និងទីផ្សារអន្តរជាតិ នេះបើយោងតាមលោក រាជ រ៉ា រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម និងជាអនុប្រធានក្រុមការងារចម្រុះរៀបចំគោលនយោបាយស្វាយចន្ទីកម្ពុជា។

ក្នុងឆ្នាំ២០២០ កម្ពុជានាំចេញគ្រាប់ស្វាយចន្ទីសរុបចំនួន ២១៨ ៩៨១ តោន ដែលកើនឡើងត្រឹមតែ ៨,២៤ % ធៀបនឹងឆ្នាំ ២០១៩។ *ដោយ មុំ ចិន្តា*

*ប្រភព៖ [ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី១០ សីហា ឆ្នាំ២០២១]*

### វិបត្តិជំងឺកូវីដ១៩ មិនអាចរារាំងការងារបង្កបង្កើនផលស្រូវរបស់ប្រជាកសិករនៅខេត្តបាត់ដំបងឡើយ



*ប្រភព៖ [CNC ២០២១]*

ក្នុងរយៈពេលជិត៤ខែកន្លងមកនេះ គឺចាប់ពីដើមខែឧសភា ឆ្នាំ២០២១មក ខេត្តបាត់ដំបងមានអំណោយផលល្អប្រសើរពីធម្មជាតិ មានភ្លៀងធ្លាក់មកជាបន្តបន្ទាប់ និងភ្លៀងធ្លាក់រាយប៉ាយ គ្របដណ្តប់ស្ទើរតែទូទាំងខេត្ត

ដែលធ្វើឱ្យការបង្កបង្កើនផលស្រូវរដូវវស្សារបស់ប្រជាកសិករ មានភាពលឿនជាងឆ្នាំមុន ។

តាមផែនការ ការដាំដំណាំស្រូវខេត្តបាត់ដំបងក្នុងឆ្នាំ ២០២១នេះ មានចំនួន៣៣ម៉ឺនហ.ត។ បើគិតត្រឹមដើមសប្តាហ៍ទី២នៃខែសីហានេះ ខេត្តដាំស្រូវរដូវវស្សាបានស្មើនឹង៨៥% និងបានលឿនជាងឆ្នាំ២០២០។

លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទខេត្តបាត់ដំបង បានបញ្ជាក់ថា ឆ្នាំនេះ ថ្វីត្បិតតែរបបទឹកភ្លៀងមានតិចជាងឆ្នាំមុន តែល្បាយទឹកភ្លៀងបានធ្លាក់រាយប៉ាយជាបន្តបន្ទាប់ តាំងពីមុនឈានចូលមកដល់នៃរដូវវស្សា ផ្តល់ឱកាសដល់កសិករងាយស្រួលក្នុងការភ្ជួររាស់ដី ហាលដី បានល្អ ជាពិសេសការសាបព្រោះ។ បើទោះបីជាឆ្នាំនេះការងារបង្កបង្កើនផលស្រូវមានសន្ទុះខ្លាំងជាងឆ្នាំមុនក៏ពិតមែន តែក៏មានជួបនូវផលប៉ះពាល់ខ្លះពីកូនរដូវប្រាំងនាពេលកន្លងមក ធ្វើឱ្យតំបន់ខ្លះស្ងើរទឹក ដែលជាតំបន់ស្ថិតនៅឆ្ងាយពីប្រព័ន្ធប្រឡាយ និងតំបន់ខ្លះមានសត្វមមាចត្នោត។ ប៉ុន្តែដោយមានការជួយសង្គ្រោះពីអាជ្ញាធរដែនដី និងមន្ត្រីជំនាញពាក់ព័ន្ធ រហូតដល់មានភ្លៀងធ្លាក់វិញ ទើបធ្វើឱ្យដំណាំស្រូវលូតលាស់បានល្អមកវិញ។

ក្រៅពីការងារដាំដុះដំណាំស្រូវ ប្រជាកសិករក៏មមាញឹកដាំដំណាំសាកវប្បកម្ម(horticulture) រួមមានពោតស ដំឡូងជ្វា បន្លែ ឪឡឹក ម្ទេស និងដំណាំឧស្សាហកម្មមានពោតក្រហម ដំឡូងមី សណ្តែកបាយ សណ្តែកសៀង សណ្តែកដី អំពៅ និងល្ង ជាដើម។

លោក បានអំពាវនាវដល់កសិករទូទៅ បើមានជួបបញ្ហាទៅលើដំណាំកសិកម្ម ដូចជាពូជ ការប្រើប្រាស់ជី ឬសត្វល្អិតបំផ្លាញដំណាំ និងបច្ចេកទេសដាំដុះផ្សេងៗទៀតនោះ សូមធ្វើការទំនាក់ទំនងមកមន្ត្រីជំនាញនៅតាមបណ្តាស្រុក ក្រុង ឬមន្ទីរកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទខេត្តបាត់ដំបងផ្ទាល់ ដើម្បីក្រុមការងារចុះជួយអន្តរាគមន៍បានទាន់ពេលវេលា ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ cnc ចេញផ្សាយថ្ងៃទី ០៩-សីហា-២០២១។*

## កម្ពុជានាំចេញស្វាយស្រស់ជាង១៦ម៉ឺនតោន ក្នុង៧ខែដំបូង ឆ្នាំ២០២១



*ប្រភព ៖ champey*

ក្នុងរយៈពេល៧ខែដំបូង នៃឆ្នាំ២០២១នេះ ការនាំចេញផ្លែស្វាយស្រស់ពីកម្ពុជាទៅក្រៅប្រទេស បានកើនឡើងចំនួន ២៤៧,៩២% ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំ២០២០។

ប្រទេសវៀតណាមជាប់លេខរៀងទី១ ក្នុងការនាំចូលស្វាយពីកម្ពុជា ប្រទេសថៃឈរលេខរៀងទី២ បន្ទាប់មកប្រទេសចិន ប្រទេសកូរ៉េ ទីក្រុងហុងកុង ប្រទេសសិង្ហបុរី និងប្រទេសគុយវ៉ែត។

ក្រៅពីការនាំចេញផ្លែស្វាយស្រស់ កម្ពុជាក៏បាននាំចេញដំណាប់ស្វាយផងដែរ ដោយបានកើនឡើងចំនួន ១៩៤,១៨% ក្នុងនោះនាំចេញទៅកាន់ប្រទេសចិន

ជប៉ុន កូរ៉េ ហ្វីលីពីន ថៃ សហរដ្ឋអាមេរិក វៀតណាម ចក្រភពអង់គ្លេស និងប្រទេសកាហ្សាក់ស្ថាន។

*ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ champey ចេញផ្សាយថ្ងៃទី០៦ ខែសីហា ឆ្នាំ២០២១។*

## ៧ខែដំបូង នៃឆ្នាំ២០២១ កម្ពុជានាំចេញអង្ករ បានជាង ៣០ម៉ឺនតោន ធ្លាក់ចុះជាង២៧%




*ដោយ: ខន ចំប៉ា*

ក្នុងរយៈពេល៧ខែដំបូង នៃឆ្នាំ២០២១នេះ កម្ពុជាបាននាំចេញអង្ករចំនួន ៣០៩ ៨៦៥តោន ទៅកាន់ទីផ្សារអន្តរជាតិចំនួន ៥៩ប្រទេស មានដូចជា អឺរ៉ុប ចិន អាស៊ាន និងបណ្តាប្រទេសផ្សេងៗទៀត។ បរិមាណនាំចេញបានធ្លាក់ចុះជាង ២៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០។ មូលហេតុនៃការធ្លាក់ចុះនេះ គឺដោយសារការខ្វះទូកុងតេន័រ សម្រាប់ផ្ទុក និងការកើនឡើងនូវតម្លៃដឹកជញ្ជូន។

បរិមាណអង្ករដែលកម្ពុជា បាននាំចេញទៅកាន់ទិសដៅសហភាពអឺរ៉ុបចំនួន២១ប្រទេស បានថយចុះជាង ៤៦% នាំទៅប្រទេសចិន មានចំនួនប្រហាក់ប្រហែលនឹងឆ្នាំ២០២០ ទៅអាស៊ាន-៥ប្រទេស ថយចុះជាង ៤៨% និងទិសដៅដទៃទៀតចំនួន២២ប្រទេស ថយចុះជិត៣០%។

ដោយឡែកនៅក្នុងខែកក្កដា ឆ្នាំ២០២១ ការនាំចេញអង្ករមានចំនួន ២៩ ៤១៥តោន កើនឡើងជាង៣% ធៀបនឹងខែកក្កដា ឆ្នាំ២០២០។ ក្នុងចំណោមអង្ករដែលបាននាំចេញមាន អង្ករក្រអូបគ្រប់ប្រភេទ អង្ករសគ្រប់ប្រភេទ និងអង្ករចំហុយ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖thmeythmeyចេញផ្សាយថ្ងៃទី០៤ខែសីហាឆ្នាំ២០២១*

# តារាងប្រចាំសប្តាហ៍

## តារាងទី១៖ ការចំណាយលើអត្ថប្រយោជន៍សង្គម ប្រចាំខែឧសភា ឆ្នាំ២០២១

តាមទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថា៖ នៅក្នុងខែឧសភា ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិបានចំណាយលើអត្ថប្រយោជន៍សង្គម ក្នុងទំហំទឹកប្រាក់សរុបចំនួន ៣៧៦,៩៤ប៊ីលានរៀល កើនឡើងយ៉ាងខ្លាំងប្រមាណជា ២៧០% បើធៀបនឹងខែមេសា។ ជាក់ស្តែង ការចំណាយលើអត្ថប្រយោជន៍សន្តិសុខសង្គម មានទឹកប្រាក់ចំនួន ៩២,៨១ប៊ីលានរៀល នៅខែឧសភាឆ្នាំ២០២១ ដែលមានការកើនឡើងគួរកត់សម្គាល់ប្រមាណជា ១៣៧,៦% បើធៀបនឹងខែមេសា។ ទន្ទឹមនឹងនោះដែរ ការចំណាយលើជំនួយសង្គមដល់ប្រជាពលរដ្ឋ មានទឹកប្រាក់ចំនួន ២៦៦,៧៨ប៊ីលានរៀល នៅក្នុងខែឧសភា ឆ្នាំ២០២១ ដែលមានការកើនឡើងយ៉ាងខ្លាំងប្រមាណជា ៣០៦,៤% បើធៀបនឹងខែមេសា។ ម្យ៉ាងវិញទៀត ការចំណាយលើអំណោយពីពហុភាគីសំរាប់ចំណាយវិនិយោគ មានទំហំទឹកប្រាក់១១,៧៣ ប៊ីលានរៀល នៅក្នុងខែឧសភា ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា១១,៧៣% បើធៀបនឹងខែមេសា។

ដោយឡែក ការចំណាយអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ទើបតែមាននៅក្នុងខែឧសភា ឆ្នាំ២០២១នេះ មានទឹកប្រាក់ចំនួន ៥,៦២ប៊ីលានរៀល។ដោយ មិត្ត ចន្ទី

| ការចំណាយឆ្នាំ២០២១ (គិតជាប៊ីលានរៀល) | មករា | កុម្ភៈ | មីនា | មេសា | ឧសភា |
|---|---|---|---|---|---|
| **អត្ថប្រយោជន៍សង្គម** | **103.40** | **114.72** | **240.59** | **115.28** | **376.94** |
| កំណើន/ថយ(%) | | 10.9% | 109.7% | -52.1% | 227.0% |
| អត្ថប្រយោជន៍សន្តិសុខសង្គម | 90.63 | 101.04 | 158.63 | 39.06 | 92.81 |
| កំណើន/ថយ(%) | | 11.5% | 57.0% | -75.4% | 137.6% |
| ជំនួយសង្គមដល់ប្រជាពលរដ្ឋ | 9.54 | 8.85 | 75.32 | 65.65 | 266.78 |
| កំណើន/ថយ(%) | | -7.2% | 751.1% | -12.8% | 306.4% |
| អំណោយពីពហុភាគីសំរាប់ចំណាយវិនិយោគ | 3.23 | 4.83 | 6.64 | 10.57 | 11.73 |
| កំណើន/ថយ(%) | | 49.5% | 37.5% | 59.2% | 11.0% |
| អត្ថប្រយោជន៍សង្គមផ្សេងៗទៀត | - | - | - | - | 5.62 |

ប្រភព៖ តារាងប្រតិបត្តិការហិរញ្ញវត្ថុនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសម្រាប់ខែឧសភាឆ្នាំ២០២១

## តារាងទី២ ៖ ពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសថៃលើមុខទំនិញ នៅក្នុងខែមិថុនា ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ធនាគារជាតិ នៃប្រទេសថៃ បានបង្ហាញថា៖ នៅក្នុងខែមិថុនា ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសថៃ មានទំហំទឹកប្រាក់ប្រមាណជា ៦១៦,២០លានដុល្លារ ដែលមានការធ្លាក់ចុះប្រមាណជា ៨,៣% បើធៀបនឹងខែឧសភា។ ជាក់ស្តែង នៅក្នុងខែមិថុនា ឆ្នាំ២០២១ ការនាំចេញទំនិញរបស់កម្ពុជាទៅប្រទេសថៃ មានទំហំទឹកប្រាក់ប្រមាណជា ៥៥,៩៣លានដុល្លារ ដែលមានការធ្លាក់ចុះប្រហែល ៣% បើធៀបនឹងខែឧសភា។

ស្របពេលនោះដែរ ការនាំចូលទំនិញរបស់ប្រទេសថៃមកកម្ពុជា មានទំហំទឹកប្រាក់ ៥៦០,២៧លានដុល្លារ ក្នុងខែមិថុនាឆ្នាំ២០២១ ដែលមានការធ្លាក់ចុះប្រមាណជា ៨,៨% បើធៀបនឹងខែឧសភា។ ដោយ មិត្ត ចន្ទី

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា |
|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **653.39** | **644.76** | **799.19** | **596.61** | **671.83** | **616.20** |
| កំណើន% | | -1.3% | 24.0% | -25.3% | 12.6% | -8.3% |
| នាំចេញ | 113.22 | 112.05 | 104.27 | 72.63 | 57.65 | 55.93 |
| កំណើន% | | -1.0% | -6.9% | -30.3% | -20.6% | -3.0% |
| នាំចូល | 540.17 | 532.71 | 694.92 | 523.98 | 614.18 | 560.27 |
| កំណើន% | | -1.4% | 30.4% | -24.6% | 17.2% | -8.8% |

*ឯកតា៖ គិតជាលានដុល្លារអាមេរិក*

ប្រភព៖ *ធនាគារប្រទេសថៃ*

# ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

## គិតត្រឹមឆមាសទី១ ការធ្វើពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងសហរដ្ឋអាមេរិក មានសន្ទុះកើនឡើងជាង៣២%



*ប្រភព៖ postkhmer, 2021 រូបភាព៖ ហេងជីវ័ន*

វិបត្តនៃជំងឺកូវីដ-១៩ នៅតែបន្តជះឥទ្ធិពលអវិជ្ជមានដល់ការធ្វើពាណិជ្ជកម្មអន្តរជាតិ។ ដោយឡែក ការធ្វើពាណិជ្ជកម្មទ្វេភាគីរវាងកម្ពុជា និងសហរដ្ឋអាមេរិក មិនបានធ្លាក់ចុះឡើយ។

តាមទិន្នន័យរបស់ការិយាល័យពាណិជ្ជកម្មអាមេរិក បានបង្ហាញថា៖ ការធ្វើពាណិជ្ជកម្មរវាងប្រទេសទាំងពីរ

ក្នុងឆមាសទី១ ឆ្នាំ២០២១ មានតម្លៃសរុបចំនួន ៣,៨ ពាន់លានដុល្លារ បានកើនឡើង ៣២,៨% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។ ក្នុងនោះការនាំចេញទំនិញពីកម្ពុជា មានតម្លៃ ៣,៦ពាន់លានដុល្លារ កើនឡើង ៣២,៤% និងការនាំចូលទំនិញពីសហរដ្ឋអាមេរិក មានតម្លៃ ២០២,៦លានដុល្លារ កើនឡើង ៤០,៣% ធៀបនឹងឆមាសទី១ ឆ្នាំ២០២០។

សម្រាប់ខែមិថុនាឆ្នាំ២០២១ កម្ពុជាបានធ្វើការនាំចេញទំនិញទៅកាន់សហរដ្ឋអាមេរិក ក្នុងតម្លៃសរុប ៥០៦,១ លានដុល្លារ កើនឡើង ៣០,៣% និងការនាំចូលត្រឡប់មកវិញមានតម្លៃ ២៨,៨លានដុល្លារ កើនឡើង ៤៩,២%។ ដោយសារ រាជរដ្ឋាភិបាលកម្ពុជាបានបញ្ចុះពន្ធគយ ចាប់តាំងពីខែមីនាឆ្នាំ២០២១ បានធ្វើឱ្យកំណើននៃការនាំចូលរថយន្តរបស់សហរដ្ឋអាមេរិកមកកម្ពុជាមានការកើនឡើង ចំណែកឯ ការនាំចេញរបស់កម្ពុជាវិញក៏មានការកើនឡើងដែរដោយសារមានតម្រូវការផលិតផលប្រើប្រាស់គ្រប់ប្រភេទជាពិសេសផលិតផលវាយនភណ្ឌ និងកង់។

សហរដ្ឋអាមេរិកគឺជាទីផ្សារធំ ដែលកម្ពុជាអាចរក្សាបានកំណើននៃការនាំចេញ ដែលអាចនឹងរួមចំណែកច្រើនក្នុងការប្រមូលចំណូលមកអភិវឌ្ឍជាតិ និងសង្គម។ នៅក្នុងឆ្នាំ២០២០ ទំហំពាណិជ្ជកម្មសរុបរវាងប្រទេសទាំងពីរមានតម្លៃសរុប ៦,៩ ប៊ីលានដុល្លារ សមាមាត្រនឹងការកើនឡើង១៧,៨៩% ធៀបនឹងឆ្នាំ ២០១៩។

*ដោយ សេន ចន្ទ*

*ប្រភព៖ postkhmer, ចេញផ្សាយថ្ងៃទី០៩ខែសីហា ឆ្នាំ២០២១*

## កំណើនសេដ្ឋកិច្ចរបស់ហ្វីលីពីនមានការកើនឡើងខ្លាំងនៅក្នុងអំឡុងពេល ៣ទសវត្សន៍កន្លងមក ប៉ុន្តែមានឧបសគ្គដោយសារជំងឺពពកខ្មៅ កូវីដ១៩



*រូបថតដោយ៖ REUTERS/Eloisa Lopez*

ទីភ្នាក់ងារស្ថិតិបានលើកឡើងថា ផ.ស.ស របស់ហ្វីលីពីនកើនឡើង ១១,៨% នៅក្នុងត្រីមាសទី២ ឆ្នាំ២០២១ បន្ទាប់ពីបានធ្លាក់ចុះដោយសារកូវីដ១៩ កាលពីឆ្នាំមុន។ នេះគឺជាកំណើនធៀបនឹងពេលដូចគ្នាកាលពីឆ្នាំមុន ដែលមានសន្ទុះខ្លាំងបំផុត បើគិតចាប់តាំងពីត្រីមាសទី៤ ឆ្នាំ១៩៨៨ ដោយសារ តម្រូវការក្នុងស្រុកមានកំណើនល្អប្រសើរ។

ក្នុងការស្ទង់មតិមួយដែលបានធ្វើឡើងដោយ REUTERS សេដ្ឋវិទូរំពឹងថា សេដ្ឋកិច្ចប្រចាំឆ្នាំរបស់ហ្វីលីពីននឹងកើនឡើង ១០% នៅក្នុងត្រីមាសទី២ ធៀបនឹងពេលដូចគ្នាកាលពីឆ្នាំ២០២១។ ប៉ុន្តែការងើបឡើងវិញនៃសេដ្ឋកិច្ចត្រូវបានរាំងស្ទះ ដោយសារតែការរីករាលដាលជំងឺកូវីដ១៩។

មានការរំពឹងទុកថា គោលនយោបាយរូបិយវត្ថុនឹងត្រូវបានអនុវត្តរហូតដល់បំណាច់ឆ្នាំ២០២១ នេះ។ ចំណែកឯអត្រាគោលនយោបាយ ត្រូវបានរំពឹងថា នឹងរក្សាបានក្នុងកម្រិតទាបជាង ២,០% ដើម្បីរក្សាស្ថិរភាពនៃការងើបឡើងវិញរបស់សេដ្ឋកិច្ច។ ការជំរុញនេះគឺជា

លទ្ធផល ដែលទទួលបានពីគោលនយោបាយទប់ស្កាត់កូវីដ១៩ និងការបង្កើនការងារ និងប្រាក់ចំណូលរបស់ពលរដ្ឋ។

ទោះយ៉ាងណា កំណើនសេដ្ឋកិច្ចមានការធ្លាក់ចុះក្នុងអំលុងពេលចាប់ពីខែមេសា ដល់ខែមិថុនាចំនួន១,៣% បន្ទាប់ពីបានកើនឡើងចំនួន ០,៣% នៅត្រីមាសទី១ កន្លងទៅ។ ចំណាយលើការប្រើប្រាស់របស់គ្រួសារ បានកើនឡើងចំនួន ៧,២% នៅត្រីមាសទី២ ធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ប៉ុន្តែ ចំណាយរបស់រដ្ឋបានធ្លាក់ចុះ ៤,៩% ដែលជាការធ្លាក់ចុះខ្ពស់មួយ ចាប់ពីឆ្នាំ ២០១៧។

ទន្ទឹមនឹងនេះ វិស័យសេវាកម្មកើនឡើង ៩,៦% និងឧស្សាហកម្មកើនឡើង ២០,៨% ខណៈដែលវិស័យកសិកម្ម ព្រៃឈើ និងនេសាទធ្លាក់ចុះ០,១%។ ប៉ុន្តែកំណើននេះអាចនឹងធ្លាក់ចុះវិញ ខណៈដែលរដ្ឋាភិបាលនៅតែបន្តរឹតបន្តឹងវិធានការនានា ដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ បំប្លែងថ្មីឈ្មោះ Delta។

លោក Dennis Mapa ប្រធានអាជ្ញាធរស្ថិតិរបស់ហ្វីលីពីនបាននិយាយថា កំណើនសេដ្ឋកិច្ចហ្វីលីពីនគួរតែកើនបាន ៨,២% នៅក្នុងឆមាសទី២ ទើបអាចសម្រេចបានគោលដៅទាបបំផុតនៃកំណើនសេដ្ឋកិច្ចប្រចាំឆ្នាំពី ៦,០% ទៅ ៧,០%៕ *ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ REUTERS ចេញផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ ២០២១*

## ការអនុវត្តថវិការបស់ប្រទេសហ្វីលីពីន ក្នុងឆមាសទី១ឆ្នាំ២០២១

ក្នុងឆមាសទី១ ឆ្នាំ២០២១ ការអនុវត្តចំណូលថវិកាជាតិសរុបរបស់ប្រទេសហ្វីលីពីន មានចំនួនPHP ១ ៤៩០ ប៊ីលាន កើនឡើង ២,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២០ ។ ក្នុងនោះ ចំណូលពន្ធមានចំនួន PHP១ ៣៤៥ ប៊ីលាន កើនឡើង ១០,៤% ចំណែកឯចំណូលមិនមែនពន្ធ(រួមបញ្ចូលទាំងជំនួយ)មានចំនួន PHP ១៤៥ ប៊ីលាន ធ្លាក់ចុះរហូតដល់ ៣៨,៥%។

ក្នុងរយៈពេលដូចគ្នានេះ ការប្រមូលចំណូលរបស់ការិយាល័យពន្ធផ្ទៃក្នុង Bureau of Internal Revenue (BIR) កើនឡើងជិត៨% ខណៈពេលដែលការប្រមូលចំណូលរបស់ការិយាល័យគយ Bureau of customs (BOC)បានកើនឡើង ១៩,២% ។

ចំណែកឯ ការចំណាយថវិកាជាតិក្នុងឆមាសទី១ ឆ្នាំ ២០២១ មានចំនួន PHP២ ២០៦ប៊ីលាន កើនឡើង ៩,៦% ក្នុងនោះចំណាយមូលធនបានកើនឡើងចំនួន ៥៣,៥% ធៀបនឹងឆ្នាំកន្លងទៅ។

## តារាងប្រៀបធៀបការអនុវត្តន៍ថវិការបស់ហ្វីលីពីន ក្នុងឆមាសទី១ (២០១៩-២០២១)

| បរិយាយ | គិតជា ប៊ីលាន ប៉េសូ (PHP) | | | កំណើន (%) | |
|---|---|---|---|---|---|
| | 2019 | 2020 | 2021 | 2020 | 2021 |
| ចំណូល | 1,548 | 1,453 | 1,490 | (6.1) | 2.5 |
| ពន្ធ | 1,381 | 1,218 | 1,345 | (11.8) | 10.5 |
| ការិយាល័យពន្ធក្នុងស្រុក | 1,066 | 956 | 1,032 | (10.3) | 7.9 |
| ការិយាល័យគយ | 303 | 253 | 302 | (16.5) | 19.2 |
| ការិយាល័យផ្សេងៗ | 12 | 8 | 12 | (29.7) | 46.40 |
| មិនមែនពន្ធ | 167 | 236 | 145 | 41.5 | (38.5) |
| ចំណាយ | 1,590 | 2,014 | 2,206 | 26.6 | 9.6 |
| មូលធន | 378 | 381 | 584 | 0.8 | 53.5 |
| តុល្យភាព | -43 | -560 | -716 | 1,213.80 | 27.8 |

*ប្រភព៖ នាយកដ្ឋានហិរញ្ញវត្ថុ ហ្វីលីពីន*

សរុបរួមមក ឱនភាពថវិកាជាតិរបស់ប្រទេសហ្វីលីពីន កើនឡើងនៅក្នុងឆមាសទី១ ឆ្នាំ២០២១ ចំនួន PHP ៧១៦ ប៊ីលានធៀបនឹងឆ្នាំ២០២០៕ *ដោយ មុំ ចិន្តា*

*ប្រភព៖ នាយកដ្ឋានហិរញ្ញវត្ថុហ្វីលីពីន*

## អ្នកកែច្នៃអាហារថៃ ស្នើសុំរដ្ឋ តម្លើងថ្លៃទំនិញ ៥ ទៅ ៧% ដោយសារថ្លៃដើមកើនខ្លាំង



*ប្រភព៖ pnn, ២០២១ រូបភាព៖ ឯកសារ*

អ្នកកែច្នៃ និងផលិតអាហារក្នុងប្រទេសថៃ បានស្នើសុំទៅនាយកដ្ឋានពាណិជ្ជកម្មផ្ទៃក្នុងថៃ តម្លើងថ្លៃអាហារកែច្នៃ ក្នុងរង្វង់៥% ទៅ៧% ព្រោះថា ថ្លៃដើមផលិតមានការកើនឡើងខ្លាំងដោយសារ បញ្ហាវត្ថុធាតុដើម ការវេចខ្ចប់ និងប្រាក់ឈ្នួលកម្លាំងពលកម្ម។ ប្រធានសមាគមអ្នកកែច្នៃម្ហូបអាហារថៃ បានលើកឡើងថា ពេលនេះ អ្នកកែច្នៃម្ហូបអាហារថៃ ប្រឈមមុខនឹងការចំណាយកាន់តែខ្ពស់ ដោយសារករណីឆ្លងមេរោគកូវីដ១៩ កើនឡើងជាបន្តបន្ទាប់។

តម្លៃនៃការវេចខ្ចប់ដោយប្រើកំប៉ុងដែក និងក្រដាស កើនឡើងដល់ទៅ២០% ធៀបនឹងឆ្នាំមុនដោយសារ តម្លៃដែក និងក្រដាសនៅលើទីផ្សារសកលមានការ កើនឡើងដូចគ្នា។ បច្ចុប្បន្នក្រុមហ៊ុនផលិតចំណីអាហារកំពុងរងបន្ទុកពីការកើនឡើងថ្លៃដើមផលិត ប្រមាណ១០% ដូច្នេះ ទើបស្នើសុំទៅរាជរដ្ឋាភិបាលថៃ តម្លើងថ្លៃទំនិញក្នុងអត្រាប្រមាណ ៥%ទៅ៧%។

បញ្ហាជាច្រើនផ្សេងទៀតក៏កើតមានឡើងផងដែរ ចំពោះអ្នកនាំចេញចំណីអាហារថៃ ដែលមានដូចជា ការកើនឡើងថ្លៃដឹកជញ្ជូន និងការប្រែប្រួលនៃរបបសេវាកម្មអាហារ ជាពិសេសភោជនីយដ្ឋាន ដែលបាត់បង់ភ្ញៀវទេសចរបរទេស និងទទួលបានការបញ្ជាទិញក្នុងកម្រិតតិចតួច។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មថៃ បានចាត់តាំងឱ្យនាយកដ្ឋានពាណិជ្ជកម្មផ្ទៃក្នុង និងលេខាធិការពាណិជ្ជកម្មអចិន្ត្រៃយ៍ ដើម្បីត្រួតពិនិត្យតម្លៃទំនិញនៅតាមទីផ្សារ និងធានាឱ្យបាននូវការផ្គត់ផ្គង់គ្រប់គ្រាន់។

ជាចុងក្រោយ តំណាងរាជរដ្ឋាភិបាលថៃក៏បានជួបជាមួយវិស័យឯកជន ដែលរួមមាន រោងចក្រឧស្សាហកម្ម អ្នកចែកចាយបោះដុំ អ្នកលក់រាយ និងម្ចាស់ហាងទំនិញ ដោយពួកគេសុទ្ធតែអះអាងថា ការផ្គត់ផ្គង់ទំនិញគឺគ្រប់គ្រាន់ទៅតាមតម្រូវការក្នុងស្រុក៕

*ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ pnn ចេញផ្សាយនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០២១*

## វៀតណាម និងចិនចុះ MoU ជំរុញពាណិជ្ជកម្មផ្លែឈើ ក្នុងពេលមានផលវិបាកពីកូវីដ-១៩



*ប្រភព៖ cambonomist, ២០២១*

វៀតណាម និងចិនបានចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នា (MoU) លើកិច្ចសហប្រតិបត្តិការក្នុងវិស័យកសិកម្ម និងការលក់ផ្លែឈើ ដោយរំពឹងថា នឹងធ្វើឱ្យពាណិជ្ជកម្មរវាងប្រទេសទាំងពីរទាក់ទងនឹងផលិតផលកសិកម្មនេះ មានភាពប្រសើរឡើង។ អនុស្សារណៈយោគយល់គ្នា រវាងប្រទេសវៀតណាម និងចិននេះ ត្រូវបានចុះហត្ថលេខាដោយសមាគមបន្លែផ្លែឈើវៀតណាម និងសមាគមជំរុញពាណិជ្ជកម្មខេត្តគ័ងស៊ី-អាស៊ានរបស់ចិន ដើម្បីបង្កើនពាណិជ្ជកម្មផ្លែឈើរវាងប្រទេសទាំងពីរ។

បច្ចុប្បន្ន វៀតណាមត្រូវបានអនុញ្ញាតឱ្យនាំចេញផ្លែឈើតែ ៩មុខប៉ុណ្ណោះទៅកាន់ប្រទេសចិន មានផ្លែស្រកានាគ ឪឡឹក គូលែន មៀន ចេក ស្វាយ ខ្នុរ សាវម៉ៅ និងផ្លែមង្ឃុត។ ក្រសួងកសិកម្ម និងអភិវឌ្ឍន៍ជនបទវៀតណាម កំពុងធ្វើការងារត្រួសត្រាយផ្លូវ សម្រាប់មុខផ្លែឈើផ្សេងទៀតដើម្បីនាំទៅទីផ្សារចិន ដូចជា ផ្លែទុរេន ក្រូចថ្លុង ផាសិន ផ្លែប៊ឺ និងដូងជាដើម។ បច្ចុប្បន្ន វៀតណាមទទួលបានអាជ្ញាបណ្ណបណ្តោះអាសន្ននាំចេញដំឡូងជ្វា និងម្ទេសទៅកាន់ប្រទេសចិនរួចហើយដែរ។

កូវីដ-១៩ បានបង្កផលប៉ះពាល់ជាច្រើនដល់ពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរ លើពាណិជ្ជកម្មកសិកម្ម ដោយនៅឆ្នាំ២០២០ មានការធ្លាក់ចុះ៤%។ បើតាមរបាយការណ៍ពីក្រសួងកសិកម្មវៀតណាម នៅ៧ខែដំបូង នៃឆ្នាំ២០២១ ការនាំចេញរបស់វៀតណាមសម្រេចបានជាង ២៨ពាន់លានដុល្លារ ហើយការនាំចូលមានជាង ២៤ពាន់លានដុល្លារ។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ cambonomist ចេញផ្សាយថ្ងៃទី០៦ ខែសីហា ឆ្នាំ ២០២១។*

# សេដ្ឋកិច្ចសកល

## ការវិនិយោគលើវិស័យដឹកជញ្ជូន និងអចលនទ្រព្យឧស្សាហកម្មក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក នឹងមានកំណើនទ្វេដង ក្នុងអំឡុងពេល៣ ទៅ ៥ឆ្នាំខាងមុខ



*សកម្មភាពដឹកជញ្ជូននៅក្នុងមជ្ឈមណ្ឌលអាស៊ីប៉ាស៊ីហ្វិក។*
*រូបថតដោយ៖ JLL Vietnam*

ការវិនិយោគលើវិស័យដឹកជញ្ជូន និងអចលនទ្រព្យសម្រាប់ឧស្សាហកម្ម នៅតំបន់អាស៊ីប៉ាស៊ីហ្វិកនឹងមានការកើនឡើងទ្វេដងនៅក្នុងរយៈពេលពី ៣ឆ្នាំ ទៅ៥ឆ្នាំទៀត

ពេលគឺអាចនឹងកើនពី ២៥-៣០ប៊ីលានដុល្លារក្នុងអំលុងពេលបច្ចុប្បន្ន រហូតដល់ ៥០-៦០ប៊ីលានដុល្លារនៅពេលខាងមុខ ដោយសារតែការវិនិយោគនៅក្នុងវិស័យដឹកជញ្ជូន និងអគារឧស្សាហកម្ម ឃ្លាំងស្តុកទំនិញ រោងចក្រផលិត និងសង្វាក់ផ្គត់ផ្គង់ផលិតកម្មមានការកើនឡើង។

ម្យ៉ាងវិញទៀត ការរីវត្តន៍របស់ពាណិជ្ជកម្មអេឡិចត្រូនិក និងសេវាកម្មរបស់ភាគីទីបីនៅក្នុងវិស័យដឹកជញ្ជូន នាំឱ្យការវិនិយោគនៅក្នុងវិស័យទាំងពីរនេះ មានការផ្សារភ្ជាប់គ្នា និងសមាសភាពរបស់ម្ចាស់អាជីកម្មនៅក្នុងវិស័យដឹកជញ្ជូន និងឧស្សាហកម្មអចលនទ្រព្យនឹងមានការផ្លាស់ប្តូរគួរឱ្យកត់សំគាល់។ លោក Tom Woolhouse ប្រធានផ្នែកដឹកជញ្ជូន និងឧស្សាហកម្មរបស់អាស៊ីប៉ាស៊ីហ្វិក នៅ JLL បាននិយាយថា ការផ្លាស់ប្តូររចនាសម្ព័ន្ធទីតាំងទ្រព្យសកម្ម និងបណ្តាញសង្វាក់ផលិតកម្មនៃការផ្គត់ផ្គង់បានប្រសព្វគ្នា ដែលពន្លឿនដល់ការវិនិយោគលើវិស័យដឹកជញ្ជូន និងតម្រូវការរបស់ម្ចាស់អាជីវកម្ម។ ការបង្កើនការវិនិយោគលើវិស័យដឹកជញ្ជូន និងវិស័យឧស្សាហកម្មអចលនទ្រព្យ គឺជាកញ្ចក់ឆ្លុះបញ្ចាំងអំពីការផ្លាស់ប្តូរយុទ្ធសាស្ត្ររបស់ម្ចាស់អាជីវកម្ម ដើម្បីជំរុញឱ្យគុណភាពទ្រព្យសកម្មកាន់តែមានភាពល្អប្រសើរ និងដើម្បីផ្លាស់ប្តូរសមាសភាពក្នុងបរិបទសេដ្ឋកិច្ចបែបថ្មី ដែលផ្អែកលើកំណើនដ៏ខ្លាំងក្លានៃពាណិជ្ជកម្មអេឡិចត្រូនិក និងសង្វាក់ផលិតកម្មផ្គត់ផ្គង់ផ្នែកបច្ចេកវិទ្យា។

ទំហំនៃការវិនិយោគនេះមានការចូលរួមពីកំណើនមួយចំនួនដូចជា៖ ការកើនឡើងនៃផលប័ត្រ ការកើនឡើងនៃកិច្ចព្រមព្រៀងធំៗ និងក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចមួយចំនួនទៀត។ ម្យ៉ាងវិញទៀត យោងតាមការព្យាករណ៍ ចាប់ពីឆ្នាំ២០២០ ដល់ឆ្នាំ២០២៥ ប្រជាជននៅតំបន់ទីប្រជុំជននៅអាស៊ីប៉ាស៊ីហ្វិក នឹងអាចកើនឡើង៤១លាននាក់ក្នុងមួយឆ្នាំៗ ដែលនៅក្នុងនោះប្រជាជនដែលមានជីវភាពកម្រិតមធ្យមអាចនឹងកើនឡើងចំនួន ៧៦០លាននាក់បន្ថែមទៀត ខណៈដែលប្រាក់ចំណូលរបស់ប្រជាពលរដ្ឋនៅអាស៊ីប៉ាស៊ីហ្វិក អាចនឹងមានកំណើនក្នុងមួយឆ្នាំ ៤% ដែលនេះជាកត្តាលីករជំរុញដល់កំណើន នៅក្នុងវិស័យនេះ។

យោងតាមការព្យាករណ៍ ការវិនិយោគនេះប្រហែលជាមានកំណើនខ្លាំងនៅប្រទេសកូរ៉េខាងត្បូង អូស្ត្រាលី និងចិន។ មួយវិញទៀត វៀតណាមគឺជាប្រទេសមួយដែលមានកំណើនទីផ្សារពាណិជ្ជកម្មអេឡិចត្រូនិកខ្លាំងជាងគេនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ជាពិសេសនៅក្នុងអំលុងឆ្នាំ២០២០ និងឆ្នាំ២០២១។ ដូចនេះការដឹកជញ្ជូន មានសារៈសំខាន់ណាស់សម្រាប់វៀតណាម នាពេលអនាគត ដោយសារតម្រូវការក្នុងស្រុក នៅក្នុងវិស័យពាណិជ្ជកម្មអេឡិចត្រូនិកនៅប្រទេសវៀតណាមមានការកើនឡើង។ ក្នុងន័យនេះ ការវិនិយោគទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធ ក៏ដូចជាការវិនិយោគរបស់វិស័យឯកជននៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ គឺជាតម្រូវការចាំបាច់។

ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ សក្តានុពលនៃការលក់ និងការជួលត្រលប់មកវិញនៅក្នុងវិស័យនេះ មានការកើនឡើងនៅទូទាំងតំបន់អាស៊ីប៉ាស៊ីហ្វិក។ ដូចនេះនាំឱ្យម្ចាស់អាជីវកម្មថ្មីៗ តែងតែស្វែងរកបច្ចេកវិទ្យាថ្មី ដើម្បីគ្រប់គ្រងឃ្លាំងស្តុកទំនិញ និងដើម្បីគ្រប់គ្រងសង្វាក់ផ្គត់ផ្គង់ផលិតកម្ម។ ហេតុនេះហើយការកើនឡើង

នៃដំណោះស្រាយផ្នែកបច្ចេកវិទ្យាស្វ័យប្រវត្តិកម្ម និងការយល់ដឹងពីសង្គម អភិបាលកិច្ច និងរចនាបថ ដែលផ្តោតលើការតម្រូវការរបស់មនុស្ស បានក្លាយទៅជាទិសដៅថ្មីនៅក្នុងវិស័យដឹកជញ្ជូន ដែលបង្កើតបានជាការដឹកជញ្ជូនអចលនទ្រព្យបែបទំនើប៕

*ដោយ វង្ស ច័ន្ទស្មើដារា*

*ប្រភព៖ គេហទំព័រ Vietnamnews ចេញផ្សាយថ្ងៃទី១០ ខែសីហា ឆ្នាំ ២០២១*

## បំណុលសាធារណៈសហរដ្ឋអាមេរិក បានកើនដល់ ២៨,៦ទ្រីលានដុល្លារ ដែលមានកំណើនក្នុងរង្វង់ ៥,២ ទ្រីលានដុល្លារ គិតពីឆ្នាំ២០២០




*ប្រភព៖ Newsweek ២០២១ រូបភាព៖ Getty*

អ្នកជំនាញការជាច្រើន បានបង្ហាញពីការព្រួយបារម្ភលើការបន្តកើនឡើងនៃបំណុលជាតិ របស់សហរដ្ឋអាមេរិក ខណៈដែលព្រឹទ្ធសភា បានដាក់ចេញនូវច្បាប់ហេដ្ឋា-រចនាសម្ព័ន្ធរបស់ខ្លួន ដែលមានតម្លៃ ១,១ទ្រីលានដុល្លារ។ ជាក់ស្តែង អ្នកវិភាគមួយចំនួន មកពី The Heritage Foundation បានធ្វើការទិតៀនអំពីច្បាប់នេះ ដោយបានលើកឡើងថា បំណុលសាធារណៈសរុបរបស់សហរដ្ឋអាមេរិក បានកើនឡើងប្រមាណជា ៥,២ទ្រីលានដុល្លារ ដែលគិតត្រឹមពីដើមឆ្នាំ២០២០ ប៉ុណ្ណោះ នាំឱ្យបំណុលសាធារណៈសរុប កើនដល់ ២៨,៦ទ្រីលានដុល្លារ។

គួរបញ្ជាក់ថា មួយផ្នែកធំនៃកំណើននៃបំណុលជាតិ ៥,២ ទ្រីលានដុល្លារនេះ គឺពាក់ព័ន្ធនឹងការគាំទ្រការឆ្លើយតបនឹងវិបត្តិជំងឺរាតត្បាតកូវីដ-១៩។ ក្នុងនោះ ទំហំទឹកប្រាក់ប្រមាណជារាប់រយប៊ីលានដុល្លារ ត្រូវបានប្រើប្រាស់លើវិធានសុខភាពសាធារណៈ និងទឹកប្រាក់ច្រើនជាង ១ទ្រីលានដុល្លារ ត្រូវបានប្រើប្រាស់ក្នុងគម្រោងធានារ៉ាប់រងនិកម្មភាព(ភាពគ្មានការងារធ្វើ) និងថ្លៃចំណាយពាក់ព័ន្ធនឹងជំងឺរាតត្បាតដ៏ទៃទៀត។

គួរកត់សម្គាល់ដែរ ទំហំបំណុលដែលបានកើនឡើងក្នុងរយៈពេលជិត២ឆ្នាំនេះគឺមានទំហំប្រហាក់ប្រហែល ឬស្មើនឹងកំណើនបំណុលជាតិ សម្រាប់រយៈពេល៣ឆ្នាំដំបូងនៃរដ្ឋបាល Trump(៥,២ទ្រីលានដុល្លារ) និងរដ្ឋបាល Obama(៥ទ្រីលានដុល្លារ)៕ ***ដោយ ជា សិរីរតន៍***

*ប្រភព៖ Newsweek ចេញផ្សាយ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១*

## តម្លៃប្រេងឆៅបានធ្លាក់ចុះ ស្របពេលករណីមេរោគកូវីដ-១៩ ប្រភេទថ្មី(Delta) មានការកើនឡើងខ្លាំង



*ប្រភព៖ CNBC ២០២១, រូបភាព៖ Kyle Grillot/Bloomberg*

តម្លៃប្រេងឆៅ បានធ្លាក់ចុះ កាលពីថ្ងៃចន្ទ(ថ្ងៃទី០៩ ខែកក្កដា) ស្របពេលមានការកើនឡើងនៃករណីជំងឺកូវីដ

បំប្លែងថ្មី ប្រភេទ Delta ដែលនាំឱ្យមានការព្រួយបារម្ភទៅលើការថមថយល្បឿននៃតម្រូវការ។

ជាក់ស្តែង ក្នុងគ្រាមួយ កុងត្រាតម្លៃអនាគតនៃប្រេងឆៅរបស់ក្រុមហ៊ុន West Texas Intermediate( crude futures) ត្រូវបានសម្រេចទូទាត់ នៅក្នុងតម្លៃទាបមួយ គឺ ៦៥,១៥ដុល្លារ ក្នុង ១បារ៉ែល ដែលបានធ្លាក់ចុះ ជាង ៤%។ ក៏ប៉ុន្តែ នៅពេលរសៀល កុងត្រានេះ មានស្ថានភាពងើបឡើងបន្តិច និងបានសម្រេចទូទាត់ ក្នុងតម្លៃ ៦៦,៤៨ដុល្លារ ក្នុង ១បារ៉ែល។ បើក្រឡេកមើលលើតម្លៃគោលអន្តរជាតិ Brent crude វិញ ត្រូវបានទូទាត់ក្នុងតម្លៃ ៦៩,០៤ដុល្លារ ក្នុង ១បារ៉ែល។

ចំណែកឯ កាលពីសប្តាហ៍មុន តម្លៃទូទាត់ក្នុងកុងត្រាទាំង២ បានធ្លាក់ចុះ ច្រើនជាង ៧% ដែលត្រូវបានចាត់ទុកជាសប្តាហ៍ដែលមានការធ្លាក់ចុះអាក្រក់បំផុត គិតចាប់តាំងពីខែតុលា ឆ្នាំ២០២០មក។ ការធ្លាក់ចុះនៃតម្លៃប្រេងនេះ បានកើតឡើងទន្ទឹមនឹង ការព្រួយបារម្ភលើតម្រូវការ និងការកើនឡើងដោយមិនរំពឹងទុកនៃសន្និធិប្រេងឆៅរបស់សហរដ្ឋអាមេរិក។

គួរបញ្ជាក់ថា តម្លៃប្រេង បានងើបឡើងវិញយ៉ាងឃើតៗ សម្រាប់ឆ្នាំ២០២០ ហើយនៅខែកក្កដា កុងត្រាតម្លៃអនាគតនៃប្រេងឆៅរបស់ក្រុមហ៊ុន West Texas Intermediate ត្រូវបានសម្រេចទូទាត់ក្នុងតម្លៃ ៧៦,៩៨ ក្នុង ១បារ៉ែល ដែលជាតម្លៃខ្ពស់មួយមិនធ្លាប់ឃើញមាន គិតចាប់ពីឆ្នាំ២០១៤មក៕

*ដោយ **ជា សិរីរតន៍***

*ប្រភព៖ CNBC ចេញផ្សាយ ថ្ងៃទី៩ ខែសីហា ឆ្នាំ២០២១*

## IMFព្យាករថា ចិននឹងជាក្បាលម៉ាស៊ីនទី១ជំរុញកំណើនសេដ្ឋកិច្ចពិភពលោក នៅក្រោយវិបត្តិកូវីដ-១៩



*រូបភាព៖ Xinhua*

ប្រទេសចិននឹងក្លាយជាក្បាលម៉ាស៊ីទី១នាំមុខអាមេរិក ក្នុងការរុញកំណើនសេដ្ឋកិច្ចពិភពលោក នៅក្រោយ ពេល[illegible]កូវីដ-១៩ ផុត ពីភពផែនដីទៅ នៅប៉ុន្មានឆ្នាំខាងមុខនេះ ដែលនឹងរួមចំណែកច្រើនជាង ១ភាគ៥ នៃកំណើនផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក នារយៈពេល៥ឆ្នាំខាងមុខ គឺចាប់ពីពេលនេះ រហូតដល់ឆ្នាំ២០២៦។ ផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក រំពឹងថា នឹងកើនឡើងជាង ២៨ទ្រីលានដុល្លារបន្ថែមទៀត គឺនឹងកើនដល់ប្រមាណ១២២ទ្រីលានដុល្លារ ៥ឆ្នាំខាងមុខនេះ។

ផលិតផលក្នុងស្រុកសរុបរបស់ពិភពលោក បានធ្លាក់ចុះអស់ជាង ២,៨ទ្រីលានដុល្លារ រួចហើយកាលពីឆ្នាំ ២០២០ ដោយសារតែការរាតត្បាតកូវីដ-១៩។ ការធ្លាក់ចុះច្រើនដូចនេះមិនធ្លាប់កើតឡើងនោះទេ គិតចាប់តាំងពីវិបត្តិសេដ្ឋកិច្ចសកលតាំងពីទសវត្សរ៍ឆ្នាំ ១៩៣០មក។

ស្ថាប័នមូលនិធិរូបិយវត្ថុអន្តរជាតិ IMF បានព្យាករថា អាមេរិកនឹងក្លាយជាប្រទេសជួយរុញកំណើនសេដ្ឋកិច្ច

សកលលំដាប់ទី២ ឥណ្ឌាស្ថិតនៅលេខរៀង៣ ហើយ ជប៉ុន និង អាល្លឺម៉ង់ស្ថិតនៅលេខរៀងទី ៤ និងលេខរៀងទី៥។

នៅក្នុងឆ្នាំ២០២១ កំណើនសេដ្ឋកិច្ចរបស់ពិភពលោក នឹងមាន៦% ដែលកំណើននេះបានមកពីកំណើនសេដ្ឋកិច្ចនៃប្រទេសនានា ពិសេសមហាអំណាចសេដ្ឋកិច្ចធំៗដូចជាអាមេរិក និងចិនជាដើម។ ប៉ុន្តែសម្រាប់ប្រទេសតូចៗអាចនឹងធ្លាក់ចូលក្នុងវិបត្តិ ដោយសារពុំមានថវិកាគ្រប់គ្រាន់ក្នុងការទំនុកបម្រុងសេដ្ឋកិច្ច និងប្រយុទ្ធប្រឆាំងនឹងកូវីដ-១៩។

IMF បានបង្កើនព្យាករថា សេដ្ឋកិច្ចរបស់អាមេរិកនឹងកើនឡើង៦,៤% ក្នុងឆ្នាំ ២០២១ បើប្រៀបធៀបទៅនឹងការព្យាករនៅខែមករា ថាមាន ៥,១%ប៉ុណ្ណោះ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ cambonomist ចេញផ្សាយខែមិថុនា ឆ្នាំ២០២១។*

## ការនាំចេញរបស់ចិនងើបឡើងក្នុងខែកក្កដា ខណៈសកម្មភាពនៅកំពង់ផែស្ទុះឡើងវិញ



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២១ រូបភាព៖ AFP*

ជាមួយការបិទខ្ទប់ដ៏តឹងរឹង និងការធ្វើតេស្តរកវីរុសទ្រង់ទ្រាយធំ បានធ្វើឱ្យសកម្មភាពនៅតាមកំពង់ផែរបស់ប្រទេសចិនងើបឡើងវិញ ពិសេសនៅក្នុងខែកក្កដា ទោះបីបាត់បង់ភាពខ្លាំងខ្លះក្តី។

ការនាំចេញមានកំណើន ដោយសារមានតម្រូវការលើទំនិញដូចជា ឧបករណ៍វេជ្ជសាស្ត្រ និងសម្ភារៈអេឡិចត្រូនិក សម្រាប់ធ្វើកិច្ចការពីផ្ទះ និងដោយសារករណីនៃវីរុសកូរ៉ូណានៅតំបន់ផ្សេងៗ ដែលធ្វើឱ្យផលិតផលចិនមានតម្រូវការកើនឡើង។ ការនាំចេញពីប្រទេសចិននៅតែមានភាពធន់នៅឆ្នាំ២០២១នេះ បើទោះបីជាចិនកំពុងបង្កើនវិធានការទប់ស្កាត់ការរីករាលនៃវីរុសបំប្លែង Delta ដែលផ្ទុះឡើង ឆ្លងរាលដាលនៅខេត្តជាច្រើន។ រីឯការនាំចូលក៏អាចទទួលបានការកើនឡើង ដោយសារការកើនឡើងតម្លៃផលិតផល។

ពាណិជ្ជកម្មរបស់ចិននៅតែខ្លាំងនៅក្នុងខែកក្កដា ទោះជាការនាំចេញកើនឡើងតិចជាងក្តីរំពឹងទុកដែលបានព្យាករចំនួន ១៩,៣% ពីឆ្នាំមុន និងការនាំចូលកើនឡើង ២៨,១% ពីរយៈពេលដូចគ្នាធៀបឆ្នាំមុន។ ទិន្នន័យចុងក្រោយ អតិរេកពាណិជ្ជកម្មទូទៅរបស់ចិនមានចំនួន ៥៦,៦ ពាន់លានដុល្លារ កើនពី ៥១,៥ ពាន់លានដុល្លារក្នុង ខែមិថុនា។

ប្រទេសចិន កំពុងធ្វើការដើម្បីទប់ទល់នឹងការកើនឡើងនៃថ្លៃដើមទំនិញ ដែលបានដាក់សម្ពាធលើសហគ្រាសតូចៗ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី០៨ ខែសីហា ឆ្នាំ២០២១។*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី១៦ ខែសីហា ឆ្នាំ២០២១

- សេដ្ឋកិច្ចជប៉ុនបានធ្លាក់ចុះ ១,០%នៅត្រីមាសទី១ ឆ្នាំ២០២១ បើប្រៀបធៀបទៅនឹងការប៉ាន់ស្មានដំបូង

- អតិរេកពាណិជ្ជកម្មរបស់ឥណ្ឌូនេស៊ី បានកើនឡើងបន្តិចមកត្រឹម១,៣២៣ពាន់លានដុល្លារនៅខែមិថុនាឆ្នាំ ២០២១

ថ្ងៃអង្គារ ទី១៧ ខែសីហា ឆ្នាំ២០២១

- កំណើនអនីកម្មភាព នៅចក្រភពអង់គ្លេស បានកើនឡើង២៥,០០០នាក់ក្នុងមួយត្រីមាស គិតត្រឹមខែឧសភាឆ្នាំ ២០២១
- កំណើនសេដ្ឋកិច្ចតំបន់អឺរ៉ូ បាន១៣,៧% ក្នុងត្រីមាសទី២នៃឆ្នាំ២០២១

ថ្ងៃពុធ ទី១៨ ខែសីហា ឆ្នាំ២០២១

- កំណើនការនាំចូលទៅកាន់ប្រទេសជប៉ុន នៅខែមិថុនាឆ្នាំ២០២១លើសការព្យាករណ៍ទីផ្សារ
- កំណើនសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅចក្រភពអង់គ្លេសបានកើនឡើង ០,៥០% ក្នុងខែមិថុនាឆ្នាំ ២០២១ ធៀបនឹងខែមុន

ថ្ងៃព្រហស្បតិ៍ ទី១៩ ខែសីហា ឆ្នាំ២០២១

- អត្រានីកម្មភាពតាមរដូវរបស់អូស្ត្រាលី បានធ្លាក់ចុះមកនៅត្រឹម៤,៩% ក្នុងខែមិថុនាឆ្នាំ ២០២១
- អតិរេកពាណិជ្ជកម្មរបស់អេស្ប៉ាញ បានកើនឡើងដល់០,១៤ ពាន់លានអឺរ៉ូនៅខែឧសភាឆ្នាំ ២០២១

ថ្ងៃសុក្រ ទី២០ ខែសីហា ឆ្នាំ២០២១

- បំណុលរបស់រដ្ឋាភិបាលនៅទួរគីបានឡើងក្នុងខែមិថុនា ធៀបនឹង ខែឧសភាឆ្នាំ ២០២១
- កំណើន ផ.ស.ស របស់ប្រទេសរុស្ស៊ី បានកើនឡើង៨,៥%នៅក្នុងខែមិថុនា ឆ្នាំ ២០២១៕